# ការសម្ភាសរបស់អ្នកមីង សុខ សុខា

កៈ អ្នកសម្ភាសឈ្មោះថា ជាង ស៊ីអ៊ាវ ខៈ អ្នកអោយគេសម្ភាសឈ្មោះថា សុខ សុខា

## ការសង្ខេបប្រវត្តិរបស់ អ្នកមីង សុខ សុខា

អ្នកមីង សុខ សុខា មានអាយុ៥៥ឆ្នាំ នៅក្នុងឆ្នាំ២០១៨ មានភេទស្រី ទីលំនៅបច្ចុប្បន្ននៅភូមិព្រែកថ្លឹង ឃុំជើងឯក សង្កាត់ដង្កោ នៅរាជធានីភ្នំពេញ។

កៈ បាទ!ចឹងជាដំបូងខ្ញុំអរគុណច្រើនមីងដែរបានអោយខ្ញុំសម្ភាសពីប្រវត្តិរបស់មីង ហើយការសម្ភាសទាំងអស់នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗអោយពួកគាត់ បានស្គាល់ហ្នឹងបានដឹងពីប្រវត្តិរបស់ឪពុកម្ដាយហ្នឹងដូនតាមីង។

ខៈ ចាំ........!

កៈ ចឹងហាសមីងចឹងនៅពេលដែរខ្ញុំបានសម្ភាសមីងហើយ ខ្ញុំហ្នឹងដាក់ការសម្ភាសទាំងអស់ហ្នឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសមីង?

ខៈ ចាំ.......!

កៈ បាទ!ចឹងសំរាប់មីងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសម្ភាសទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរទេមីង ដូចជាអើប្រវត្តិរបស់មីងដែរខ្ញុំចង់ពិភាក្សាជាមួយមីងអាចដាក់ទៅក្នុងវេបសាយសាលាដើម្បីតំកល់ទុកអោយកូនចៅរបស់មីងបានស្ដាប់បានដឹងចឹងហាសមីង?

ខៈ ចាំ!ប៉ុន្តែខ្ញុំខ្លាចនិយាយទៅខុសហាសលោកគ្រូ។

កៈ អូ!អត់អីទេអ្វីដែរមីងនិយាយទាំងអស់គឺអត់ខុសទេមីង?

ខៈ ចាំ.........!

ក៖
ដោយសារតែគ្រាន់តែជាប្រវត្តិរបស់មីងចឹងមីងដឹងចឹងហាសមីងភាគច្រើនមីងនិយាយអត់ខុសទេគ្រាន់តែ ពេលខ្លះមីងភ្លេចភ្លាំងអីដែរចឹងហាស?

ខ៖ ចាំៗ.......!

ក៖ ប៉ុន្តែអត់ជាមានបញ្ហាអីទេមីងមួយហ្នឹងហោសចឹងអត់អីទេណោះមីងណោះ?

ខ៖ ចាំ........!

ក៖
បាទ!មីងប្រហែលខ្ញុំអាចសុំពិភាក្សានៅជិតមីងបន្តិចដើម្បីអោយលឺសំលេងមីងអីដែរចឹងហាសមីង?

ខ៖ ចា.......!

ក៖ បាទ!ចឹងសំរាប់ដូចជាខ្ញុំជាអ្នកសម្ភាសមីងខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ
ហើយថ្ងៃខែដែរខ្ញុំសម្ភាសមីងនៅថ្ងៃទីថ្ងៃហ្នឹងថ្ងៃទីប៉ុន្មានមីង?

ខ៖ ប្រាំមួយ......!

ក៖ ថ្ងៃទីប្រាំមួយ......?

ខ៖ ចាំ!មិនទាន់ហែកផង។

ក៖ ថ្ងៃទីប្រាំតើមីង?

ខ៖ ទីប្រាំរឺប្រាំមួយ។

ក៖ ថ្ងៃទីប្រាំខែប្រាំ ឆ្នាំ២០១៨ ?

ខ៖ ចាំ........!

ក៖ សម្ភាសភូមិនេះភូមិអីគេ?

ខ៖ ព្រែកថ្លឹង.......!

ក៖  ភូមិព្រែកថ្លឹងណោះមីងណោះ?

ខ៖ ចា៎........!

ក៖ អើសង្កាត់.......?

ខ៖ ឃុំជើងឯក.......!

ក៖ ឃុំជើងឯក សង្កាត់ដង្កោ?

ខ៖ ចា៎!សង្កាត់ដង្កោ។

ក៖ ខ័ណ្ឌនៅភ្នំពេញ?

ខ៖ ចា៎.......!

ក៖ អើចឹងសំរាប់មីងឈ្មោះពេញរបស់មីងឈ្មោះអីគេមីង?

ខ៖ ខ្ញុំឈ្មោះសុខ សុខា។

ក៖ ចុះមានឈ្មោះហៅក្រៅអត់មីង?

ខ៖ អត់ទេ.......!

ក៖ អត់មានទេ......?

ខ៖ ចា៎.......!

ក៖ ចុះកាលពីក្មេងធ្លាប់មាននរណារីមួយក៏មិត្តភក្តិមីងហៅឈ្មោះមីងអីផ្សេងទេមីង?

ខ៖ អត់ទេម៉ែប៉ាដាក់ឈ្មោះចឹងម៉ង។

ក៖ ចឹង.......?

ខ៖ ចា៎.......!

ក៖ ចុះសព្វថ្ងៃមីងអាយុប៉ុន្មានដែរមីង?

ខ៖ ខ្ញុំហាប្រាំលោកគ្រូ។

ក៖ មីងអាយុហាប្រាំឆ្នាំណោះមីងណោះ?

ខ៖ ចា៎........!

កៈ ចុះមីងកើតនៅថ្ងៃខែឆ្នាំណាមីងចាំទេ?

ខៈ អត់ផង......!

កៈ ចុះអើមីងកើតថ្ងៃខែក៏មីងអត់ចាំដែរណោះមីងណោះ?

ខៈ ចាំ........!

កៈ ចឹងមីងកើតនៅឆ្នាំអីគេមីងឆ្នាំច័ន្ទគតិហាសជូត ឆ្លូវ ខាល ថោះហាសមីងឆ្នាំអីគេ?

ខៈ ចាំ!ខ្ញុំចង់និយាយថាខ្ញុំកើតឆ្នាំរោងហាសលោកគ្រូ។

កៈ ឆ្នាំរោងណោះមីងណោះ?

ខៈ ចាំ.......!

កៈ ចឹងមីង.......?

ខៈ ដូចជាហុកបីទេមិនដឹង។

កៈ មីងកើតនៅឆ្នាំមួយពាន់ប្រាំបួនរយហុកបីមីង?

ខៈ ចាំ........!

កៈ បាទ!ចឹងសំរាប់មីងកើតនៅណាមីង?

ខៈ ខ្ញុំកើតនៅតីឡូលេខប្រាំមួយលោកគ្រូ។

កៈ ចុះភូមិអី ឃុំអីមីង?

ខៈ អត់ស្គាល់កាលណុងខ្ញុំនៅតូចហាសលោកគ្រូ។

កៈ អូ៎!ប៉ុន្តែដឹងតែតីឡូលេខប្រាំមួយ?

ខៈ ចាំ......!

កៈ សង្កាត់.......?

ខៈ ចាំ!អាអូនដេញគោអាអូន។

កៈ សង្កាត់ឬស្សីកែវអើយ៉ាស់?

ខ៖ ស៊ីខ្នុរអស់មើលគោ។

ក៖ ចឹងមីងសំរាប់នៅណុងខ័ណ្ឌឬស្សីកែវមែនទេមីង?

ខ៖ ចា៎!ខ័ណ្ឌឬស្សីកែវលោកគ្រូ។

ក៖ នៅរាជធានីភ្នំពេញ?

ខ៖ ចា៎……!

ក៖ ចឹងចុះអើដូចជាមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរមីង?

ខ៖ ខ្ញុំមានបងប្អូនចំនួនប្រាំនាក់តែស្លាប់អស់ហើយ។

ក៖ នៅសល់តែប៉ុន្មាននាក់ទៅមីង?

ខ៖
អើចង់និយាយថាស្លាប់អស់បីទៅអាពតនៅសល់ស្លាប់អស់ពីរទៅអាពតនៅសល់បីលោកគ្រូ។

ក៖ ឥឡូវនៅសល់បីណោះមីងណោះ?

ខ៖ មិនមែនទេលោកគ្រូអើចង់និយាយថាអើបែកអាពតហ្នឹងមកបែកមួយលោកគ្រូ។

ក៖ អ៊ូ…….!

ខ៖ ហើយឥឡូវហ្នឹងស្លាប់មួយបាត់ទៅហើយ។

ក៖ ចឹង…….!

ខ៖ ស្លាប់ចំនួនដប់ឆ្នាំហើយលោកគ្រូ។

ក៖ ចឹងមានន័យថាសព្វថ្ងៃនៅរស់ប៉ុន្មាននាក់មីង?

ខ៖ ម្នាក់ឯង……!

ក៖ តែម្នាក់ឯងទេហោសមីង?

ខ៖ ចា៎……!

កៈ អូ៎!ចឹងពួកគាត់ស្លាប់នៅជំនាន់ប៉ុលពតខ្លះ ហ្នឹងស្លាប់នៅក្រោយប៉ុលពតហើយ?

ខៈ ចា៎.......!

កៈ អូ៎!បាទមីង ចុះកាលបងប្អូនរបស់មីងនៅរស់ហ្នឹងដូចជាបងប្អូនរបស់មីងមានស្រីប៉ុន្មានប្រុសប៉ុន្មានមីង?

ខៈ តែប្រុសម្នាក់ដែរបែកហ្នឹងលោកគ្រូ។

កៈ ក្រៅពីហ្នឹងស្រីទាំងអស់?

ខៈ ចា៎!ស្រីពីរ ប្រុសមួយ ប្រុសហ្នឹងបែកហើយលោកគ្រូ។

កៈ អូ៎បាទ.......!

ខៈ បែកចិតប្រាំបួនហ្នឹង។

កៈ អូ៎!ប៉ុន្តែមីងជាកូនទីប៉ុន្មានមីង?

ខៈ ខ្ញុំកូនទីពីរ......។

កៈ អូ៎!ប៉ុន្តែមីងអាចប្រាប់ឈ្មោះបងប្អូនមីងទាំងអស់បានទេ
បងប្អូនមីងចាំឈ្មោះទាំងអស់ទេមីង?

ខៈ បាន.......!

កៈ គាត់ឈ្មោះអីគេខ្លះទៅមីង?

ខៈ អើឈ្មោះៗឈ្មោះបងគេបង្អស់ឈ្មោះសុខ ហ៊ុន។

កៈ ចុះបន្ទាប់មកមីង?

ខៈ បន្ទាប់មកខ្ញុំឈ្មោះសុខា។

កៈ ចុះប្អូនទីបី......?

ខៈ បន្ទាប់ដែរបែកហ្នឹងអើឈ្មោះសុខ ជា។

កៈ ចុះទីបួនមីង......?

ខ៖ ទីប្អូនឈ្មោះសុខំ។

ក៖ ចុះពៅវិញមីង?

ខ៖ ឈ្មោះសុខពៅលីនដា។

ក៖
អ៊ូ!ប៉ុន្តែមីងមានចាំអនុស្សាវរីយ៍អីកាលពីមីងនៅជាមួយបងប្អូនរបស់មីងធ្លាប់លេងអីកាលនៅក្មេងៗទេមីង?

ខ៖ អត់ទេលោកគ្រូ។

ក៖ ដូចថាលក្ខណៈថាលេងឡឹកបាយឡលេងបិតបួនអីដែរមានទេ?

ខ៖ អត់ទេ.......!

ក៖ ទៅស្រែទៅអីជាមួយគ្នាហាស?

ខ៖ អត់ទេ......!

ក៖ អត់ទេណោះមីងណោះ?

ខ៖ ចាំ.......!

ក៖ ប៉ុន្តែដូចជាគាត់ស្លាប់នៅជំនាន់ប៉ុលពត?

ខ៖ អ្នកណាលោកគ្រូ?

ក៖ មើលដូចជាបងប្អូនរបស់មីងហាសស្លាប់នៅជំនាន់ប៉ុលពតមានអត់មានហោស?

ខ៖ ចាំ!ស្លាប់មួយពៅ។

ក៖ អ៊ូប៉ុន្តែ......?

ខ៖ ស្លាប់ពីសង្គមមួយ។

ក៖ ប៉ុន្តែកើតអីបានគាត់ស្លាប់នៅជំនាន់ណុងមីង?

ខ៖ អើនិយាយរួមទៅអើខ្ញុំទៅបាត់ដំបងហាសលោកគ្រូ។

កៈ អូ៎.......!

ខៈ ហើយវាចាញ់ហាសពីតូចហាស។

កៈ បាទមីង.......!

ខៈ វាតូចទើបបីខួប។

កៈ អូ៎!ចឹងប៉ុន្តែមិនមែនស្លាប់ដោយសារមូលហេតុអីផ្សេងទេណោះដោយសារ......?

ខៈ ចាំ........!

កៈ អូ៎បាទមីង!ចុះសំរាប់ឪពុករបស់មីងគាត់ឈ្មោះអីគេដែរមីង?

ខៈ ឈ្មោះសុខ សុំ......។

កៈ សុខ សុំ.......?

ខៈ ចាំ.......!

កៈ ចុះប៉ុន្តែឥឡូវគាត់ស្លាប់ហើយមែនទេរឺមួយក៏......?

ខៈ ស្លាប់ហើយលោកគ្រូ។

កៈ អូ៎!ចុះដូចជាគាត់ដល់ឥឡូវគាត់អាយុប៉ុន្មានមីងដឹងទេមីង?

ខៈ ខ្ញុំដឹងលោកគ្រូ។

កៈ គាត់អាយុប៉ុន្មានទៅ?

ខៈ អូនដេញឆ្អែកូនអើគាត់អាយុអើទាំងជំនាន់ប៉ុលពតហ្នឹងហាសលោកគ្រូ?

កៈ អូ៎.......!

ខៈ គាត់ហុកជាងហើយ។

កៈ បាទមីងបាទ......!

ខៈ ប៉ុន្តែឥឡូវមួយរយជាងហើយលោកគ្រូ។

កៈ បាទត្រូវមីងត្រូវ?

ខ៖ សាមសិបឆ្នាំជាងហើយណាស់។

ក៖ បាទត្រូវមីង!ចុះមីងគិតថាអើគាត់កើតនៅណាឪពុករបស់មីងហាសមីងចាំទេ?

ខ៖ អើគាត់កើតនៅខ្ទួញ។

ក៖ នៅខ្ទួណ.......?

ខ៖ នៅខ្ទួញហាស.......!

ក៖ ខ្ទួញនៅណាមីង?

ខ៖ ខ្ទួញក្រយ៉ាកប់ស្រូវយើងហ្នឹង។

ក៖ អូ៎!នៅកប់ស្រូវយើងនេះទេហោស?

ខ៖ ចា៎ៗ.......!

ក៖ អូ៎បាទ.......!

ខ៖ អាហ្នឹងស្រុកកំណើតឪពុកខ្ញុំ។

ក៖ បាទ!ចុះម្ដាយរបស់មីងគាត់ឈ្មោះអីគេមីង?

ខ៖ ទឹម ហាយ.......!

ក៖ ឈ្មោះទឹម ហាយ.......?

ខ៖ ចា៎.......!

ក៖ ចុះគាត់អាយុប៉ុន្មានដែរគាត់ប្អូនតាប៉ុន្មានឆ្នាំមីង?

ខ៖
ប្អូនតាអើគាត់មិនដឹងថាឆ្នាំអីទេតែទៅអាពតដែរគាត់ស្លាប់ហ្នឹងអាយុសាមជាងហាសលោកគ្រូ។

ក៖ អូ៎!បាទចុះមីងគិតថាយាយគាត់កើតនៅណា?

ខ៖ គាត់កើតនៅអើនៅប្រសិទ្ធិលោកគ្រូ។

កៈ អ៎ូ!នៅភ្នំប្រសិទ្ធិហោស?

ខៈ ចា៎.......!

កៈ
ចុះមីងគិតថាអើមីងធ្លាប់មានដូចជាមីងធ្លាប់មានប្រវត្តិអីកាលមីងនៅជាមួយឪពុកម្ដាយរបស់មីងមីងធ្វើគេជាមួយគាត់ទេ?

ខៈ អត់មានប្រវត្តិទេលោកគ្រូដឹងតែទៅរៀន ដឹងតែទៅរៀនមកពីរៀនអើនៅផ្ទះចឹងម៉ង។

កៈ អ៎ូចឹងហោស......!

ខៈ អត់ដែរធ្វើអីទេ។

កៈ បាទ.......!

ខៈ  ព្រោះដើមឡើយពុកខ្ញុំធ្វើការជាមួយកុងសីហាស។

កៈ បាទៗ!មីងចុះមីងគិតថាដូចជាឪពុករបស់មីងកាលគាត់នៅរស់គាត់ធ្វើអីគេសំរាប់ចិញ្ចឹមក្រុមគ្រួសារហ្នឹងចិញ្ចឹមជីវិតហាសមីង?

ខៈ ចា៎!អើគ្រាន់តែខ្ញុំដឹងក្ដីភ្លាមគាត់អើដាំឈូកលោកគ្រូ។

កៈ បាទមីង......!

ខៈ ដាំឈូកហាស......!

កៈ បាទ......!

ខៈ ឈូកខ្ញុំធំហាសបឹងឈូសបាញ់មួយកាំភ្លើងអត់ដល់ទេ។

កៈ អ៎ូ........!

ខៈ កូនងុយគេងហោស។

កៈ បាទ!មីងបាទចឹងគាត់ធ្វើមួយសំរាប់ចិញ្ចឹមក្រុមគ្រួសារមីង?

ខៈ ចា៎!គ្រាន់តែខ្ញុំគ្រាន់តែថាខ្ញុំដើរខ្ញុំគ្រាន់តែចាប់ដឹងក្ដីតិចៗគាត់ដាំឈូកហាសលោកគ្រូ។

កៈ បាទមីងបាទ.......!

ខ៖ អស់ពីដាំឈូកទៅគាត់ទៅធ្វើការជាមួយកុងសី។

ក៖ អូ៎!បាទ ចុះគាត់ស្លូរឺមួយក៏កាចមីង?

ខ៖ ឪពុកខ្ញុំស្លូតហាស។

ក៖ ចឹងហោស......!

ខ៖ ចា៎......!

ក៖ ចុះម្ដាយរបស់មីងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិត ចិញ្ចឹមក្រុមគ្រួសារមីង?

ខ៖ អត់នៅតែផ្ទះដូចលោកស្រីចឹង។

ក៖ អូ៎!នៅតែផ្ទះហោសមីងចុះ......?

ខ៖ ចា៎!គាត់អាងគាត់ក្មេង។

ក៖ បាទ!មីងចុះគាត់ស្លូតរឺមួយក៏កាចម្ដាយមីង?

ខ៖ អូយកាចណាស់។

ក៖ គាត់កាចហោសមីង?

ខ៖ កាចហាសលោកគ្រូ។

ក៖ អូ៎បាទ!ចុះអើឪពុករបស់មីងគាត់ធ្លាប់ប្រាប់ពីប្រវត្តិកាលគាត់នៅក្មេងទៅមីងទេ?

ខ៖ ប្រាប់ដែរតើលោកគ្រូ។

ក៖ គាត់ធ្លាប់ធ្វើអីគេខ្លះទៅមីង?

ខ៖ គាត់អត់ធ្វើអីផងគ្រាន់តែថាគាត់នៅតូចគាត់បួស។

ក៖ អូ៎.......!

ខ៖ គាត់នៅវត្តលោកគ្រូ។

ក៖ បាទមីងបាទ.......!

ខ៖ ចុះពីវត្តគាត់បួសបួសរហូតបានធ្វើជាគ្រូសង្គ្រាចហាសលោកគ្រូ។

កៈ អ៎ូបាទមីងបាទ.......!

ខៈ ចា៎!ហើយដល់ហើយម្ដាយឪពុកហ្នឹងចេះ អើមាមីងលោកគ្រូ។

កៈ បាទ.......!

ខៈ លោកក្មួយអើយលោកគ្រូក្មួយឯងបួសម្លឹងៗអត់មានអ្នកស្នងត្រកូលចឹងទៅណាស់។

កៈ បាទមីងបាទ.......!

ខៈ ដល់ពេលចឹងសំរេចចិត្តថាសឹកទៅ។

កៈ សឹកដើម្បីទៅរកគ្រួសារទៅ?

ខៈ ចា៎.......!

កៈ ចុះម្ដាយមីងវិញគាត់ធ្លាប់ប្រាប់ពីប្រវត្តិកាលគាត់នៅក្មេងទៅមីងទេ?

ខៈ
គាត់ធ្លាប់និយាយដែរលោកគ្រូនិយាយថាកាលគាត់នៅក្មេងគ្រាន់តែគាត់ថាគាត់បងគេហាសលោកគ្រូ។

កៈ បាទមីង.......!

ខៈ ដល់ពេលដែរគាត់កើតជំងឺដំបៅមាត់។

កៈ បាទ.......!

ខៈ ហូបបាយចេញបាយ ហូបទឹកចេញទឹក។

កៈ ម៉េចចឹងមីង.......?

ខៈ ចា៎!ដល់ពេលគាត់ស្លាប់ទៅគាត់បានកើតម៉ែដដែលហ្នឹងគាត់កើតជាប្អូនពៅវិញ។

កៈ អ៎ូ!ចឹងណោះមីងណោះ?

ខៈ ចា៎.......!

កៈ បាទ!ចុះយាយតាខាងឪពុកមីងស្គាល់ឈ្មោះគាត់ទេ?

ខ៖ យាយ........!

ក៖ យាយតាខាងឪពុករបស់មីងហាស?

ខ៖ អត់ទេលោកគ្រូ។

ក៖ សូម្បីតែគាត់កើតនៅណាគាត់ឈ្មោះអីក៏មីងអត់ដឹងដែរ?

ខ៖ អត់ទេស្គាល់តែយាយខាងម្ដាយមួយគត់។

ក៖ តាខាងម្ដាយក៏អត់ស្គាល់ដែរ?

ខ៖ អត់........!

ក៖ ចុះយាយខាងម្ដាយគាត់ឈ្មោះអីគេមីង?

ខ៖ ឈ្មោះយាយទូចក

ក៖ យាយទូច.......?

ខ៖ ចាំ.......!

ក៖ ប៉ុន្តែគាត់នៅណាមីងដឹងអត់ពួកគាត់អ្នកនៅណាកើតនៅណា?

ខ៖ អត់ដឹងលោកគ្រូ។

ក៖ ចឹងណោះមីងណោះ?

ខ៖ ចាំ.......!

ក៖ ចុះមីងមករស់នៅហ្នឹងយូរនៅមីង?

ខ៖ យូរហើយលោកគ្រូតាំងពីចិតប្រាំបួនម្ល៉េសលោកគ្រូ។

ក៖ ចិតប្រាំបួនរហូតមកដល់ឥឡូវប្រហែលសាមសិបប្រាំបួនឆ្នាំហើយណោះមីង?

ខ៖ ចា!ខ្ញុំអត់ចូលស្រុកកំណើតទេពីព្រោះតែអត់ពីម្ដាយឪពុកទៅ។

ក៖ បាទមីងបាទ!ប៉ុន្តែស្រុកមីងនៅគីឡូលេខប្រាបួន?

ខ៖ ចាំ!គីឡូលេខប្រាំមួយលោកគ្រូ។

កៈ គីឡូលេខប្រាំមួយហោស?

ខៈ ចាំ.......!

កៈ
បាទមីង!ចុះមីងគិតថាមានបងប្អូនរឺមួយក៏កូនចៅរឺមួយក៏ជីដូនមួយណាដែរទៅរស់នៅក្រៅប្រទេសអត់មីង?

ខៈ អត់ទេលោកគ្រូ។

កៈ អត់មានទេ......?

ខៈ ចាំ......!

កៈ ចឹងមានតែនៅខ្មែរហ្នឹងទាំងអស់គ្នា?

ខៈ
មិនមែនទេជាចង់និយាយថាខ្ញុំអើលោកពុកខ្ញុំអើស្រុកកំណើតនៅខ្នួញក្រយ៉ាកប់ស្រូវលោកគ្រូ។

កៈ បាទ......!

ខៈ ចឹងគាត់ចេញតែម្នាក់គាត់ទេដែរទៅនៅអើគីឡូលេខប្រាំមួយ។

កៈ បាទ.......!

ខៈ ចឹងពួកខ្ញុំកើតមកតូចៗមិនអាចស្គាល់មីងមាណាបានទេ។

កៈ អ៊ូ........!

ខៈ
ស្គាល់នៅពេលដែរបុណ្យទានអីចឹងហាសយើងទៅលេងចឹងស្គាល់តែមួយភ្លែតហ្នឹងលោកគ្រូ។

កៈ បាទមីងបាទ.......!

ខៈ ដល់ជំនាន់ប៉ុលពតចូលមកចឹងយើងរឹតតែបែកឆ្ងាយទៀតហាសលោកគ្រូ។

កៈ បាទមីងបាទត្រូវ ប៉ុន្តែចង់និយាយថាមានបងប្អូនណា
រឺមួយក៏កូនក្មួយមីងណាដែរទៅធ្វើការនៅថៃ រឺវៀតណាមអត់?

ខៈ អត់ទេលោកគ្រូ។

កៈ ចឹងមានតែនៅខ្មែរហ្នឹងទេណោះមីង?

ខៈ ចា៎.......!

កៈ អូ៎បាទ!ចុះស្វាមីរបស់មីងឈ្មោះអីគេមីង?

ខៈ ឈ្មោះរឿង សុង......!

កៈ ចុះមីងមានចងចាំថាមីងរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាទេមីង?

ខៈ អត់ផងលោកគ្រូ។

កៈ ប៉ុន្តែមីងរៀបការប៉ុន្មានក៏មីងអត់ដឹងថាប៉ុន្មានឆ្នាំដែរណោះមីង?

ខៈ អើចង់និយាយថាខ្ញុំរៀបការតាំងពីឆ្នាំប៉ែតប្រាំមួយលោកគ្រូ។

កៈ ប៉ែតប្រាំមួយ......?

ខៈ ប៉ែតប្រាំចុះព្រោះខ្ញុំការបានមួយឆ្នាំខ្ញុំមានកូនខ្ញុំការប៉ែតប្រាំមួយហាសលោកគ្រូ។

កៈ អូ៎!ចឹងមានន័យថាតាំង
ពីឆ្នាំប៉ែតរហូតមកដល់ឥឡូវប្រហែលជាសាមសិបឆ្នាំជាងណោះមីង
ដូចជាសាមសិបបីឆ្នាំអីណោះមីងណោះ?

ខៈ ចា៎!កូនខ្ញុំសាមមួយហើយ។

កៈ អូ៎បាទ!ចឹងចុះមីងគិតថាអើដូចជាមីងរៀបអាពាហ៍ពិពាហ៍ជាមួយពូហ្នឹង
ដូចជាមីងជាអ្នករៀបចំដោយខ្លួនឯងរឺមួយក៏ឪពុកម្ដាយជាអ្នករៀបចំអោយមីង?

ខៈ អើរៀបចំអើ.......!

កៈ ចុះ........?

ខៈ ដោយខ្លួនឯងលោកគ្រូអត់មានម៉ែឪផងហ្នឹង។

កៈ អ៊ូចឹងហោស.......!

ខៈ គាត់ក៏ដូចគ្នា.......!

កៈ អ៊ូ!តែគាត់អត់មានឪពុកម្ដាយដូចគ្នា?

ខៈ អត់ទេមានតែប្អូនមួយស្រី ខ្ញុំមានបងមួយស្រី។

កៈ
បាទមីងបាទ!ចុះដូចជាពូចូលស្ដីដណ្ដឹងមីងហ្នឹងមានជាថ្លៃទឹកដោះអត់មីងជូនមីងហាស?

ខៈ កាលណុងអត់មានទេលោកគ្រូ។

កៈ អត់មានទេណោះ?

ខៈ តិចថាមានលុយមកផ្សំរៀងខ្លួនហាសលោកគ្រូ ហើយក៏រៀបចំការចឹងទៅ។

កៈ បាទមីងបាទ......!

ខៈ ចាំ......!

កៈ ចុះដូចជាពូស្គាល់មីងអស់រយៈពេលប៉ុន្មានឆ្នាំហើយបានពូចូលស្ដីដណ្ដឹងមីង?

ខៈ អើរយៈពេលតែមួយឆ្នាំទេលោកគ្រូ។

ខៈ ចាំ......!

កៈ មួយឆ្នាំណោះ.......?

កៈ ប៉ុន្ដែមីងមានចាប់អារម្មណ៍ថាពូមានចាប់អារម្មណ៍មីងត្រង់ណា
រឺមួយក៏មានអនុស្សាវរីយ៍អីជាមួយគ្នា?

ខៈ អើដូចអត់ចាប់អារម្មណ៍លោកគ្រូតែចង់និយាយថាគាត់ចាស់ជាងខ្ញុំមួយជួរលោកគ្រូ
គាត់អាយុហុកជាងហើយណាស់។

កៈ បាទមីង.......!

ខៈ តែចង់និយាយថាជំនាន់ហ្នឹងអើចង់និយាយថាយើងអត់ម៉ែអត់ឪចឹងលោកគ្រូអើយ។

កៈ បាទ.......!

ខ៖ចេះចង់មានមែកតោងចឹងហាសលោកគ្រូ។

ក៖ បាទមឹងបាទត្រូវ....!

ខ៖ចា៎.......!

ក៖ អ្ហ៎!ចឹងណោះមីងណោះ ចុះមីងគិតថាមីងធ្លាប់រៀនភាសាខ្មែរទេមីងពីមុនមកហាស?

ខ៖ខ្ញុំរៀនតើលោកគ្រូតែអត់រៀនអីជ្រៅជ្រះទេគ្រាន់តែអាចមើលរូចតិចៗ។

ក៖ មីងរៀនបានថ្នាក់ទីប៉ុន្មានទៅ?

ខ៖ទីបី.......!

ក៖ ទីបីណោះមីងណោះ?

ខ៖ចា៎......!

ក៖ អ្ហ៎!ចុះកាលមីងរៀនមីងរៀននៅណាមីង?

ខ៖ខ្ញុំរៀនសាលាព្រៃកថ្លឹងលោកគ្រូ។

ក៖ ព្រៃកថ្លឹងណោះមីងណោះ?

ខ៖ចា៎.......!

ក៖ ប៉ុន្តែឈ្មោះសាលាឈ្មោះអីគេមីងមានចាំទេ?

ខ៖អើសាលាបឋមសិក្សាហ៊ុននាង។

ក៖ អ្ហ៎!ហ៊ុននាងណោះមីងណោះ?

ខ៖ចា៎.......!

ក៖ អ្ហ៎មីង!មីងដាំបបរហោសមីង?

ខ៖អត់ផង......!

ក៖ អត់ទាន់ដាំទេហោស?

ខ៖ចា៎!អត់អីទេលោកគ្រូ។

កៈ អូ៎!ខ្ញុំខ្លាចមីងដាំបបរ?

ខៈ ដាំឆ្អិនហើយ.......!

កៈ អូ៎បាទ!ចុះមីងគិតថាអើដូចជាកាលមីងរៀននៅសាលាហ៊ុននាងហ្នឹង មីងមានធ្លាប់មានមិត្តភក្តិស្និទ្ធិស្នាលជាមួយគ្នាដែរធ្លាប់ដើរលេងអីជាមួយគ្នាទេមីង?

ខៈ មានតើលោកគ្រូ។

កៈ ប៉ុន្តែមានច្រើនទេមីង?

ខៈ មានចេះច្រើនហើយតែរាប់អាននៅសល់តែម្នាក់។

កៈ អូ៎........!

ខៈ ចឹងនិយាយចឹង.......!

កៈ ប៉ុន្តែគាត់ឈ្មោះអីគេមីង?

ខៈ អើគាត់ឈ្មោះខិន ស្រីនាង។

កៈ តែគាត់នៅណាឥឡូវមីង?

ខៈ ឥឡូវនៅបាត់ដំបងហោសលោកគ្រូ។

កៈ អូ៎!នៅបាត់ដំបងហោសមីង ប៉ុន្តែយើងនៅតែទាក់ទងគ្នារហូតតើហីមីង?

ខៈ ចា៎.......!

កៈ ប៉ុន្តែមីងមានចងចាំអនុស្សាវរីយ៍អីកាលមីងដើរលេងអីជាមួយពួកគាត់ទេមីង កាលនៅក្មេងៗនៅរៀនជាមួយគ្នាហាស?

ខៈ
អើជំនាន់ណុងគ្មានដើរលេងទេលោកគ្រូអើយគ្រាន់តែថាយើងរៀនៗសិស្សានុសិស្សហ្នឹង លោកគ្រូ។

កៈ បាទមីង.......!

ខ៖
ពេលអើបងប្អូនណាត្រូវការច្រូតចឹងថ្ងៃអាទិត្យទៅជួយច្រូតគាត់រឺមួយថ្ងៃព្រហស្បត្តិ៍អីចឹង ហាសលោកគ្រូ។

ក៖ អ៎ូបាទមីងបាទ.......!

ខ៖ ចាំ!ច្រូតគេអោយតែច្រូតទេស្ទូងអត់ហ៊ានទៅទេ។

ក៖ អ៎ូបាទមីង!ចុះមីងគិតថាធ្លាប់ដើរលេងអីជាមួយគ្នាធ្លាប់ញ៉ាំបាយញ៉ាំអីជាមួយគ្នាដែរ មានអនុស្សាវរីយ៍មួយដែរមីងចាំអត់ភ្លេចហាសមានទេ?

ខ៖ ចាំអត់ភ្លេចទៅរាវលាសលោកគ្រូ។

ក៖ អ៎ូ!រាវលាសជាមួយគ្នាហោស?

ខ៖ ចាំ......!

ក៖ នៅណាមីងនៅតាមព្រែក?

ខ៖ អ៎ូ!នៅបឹងអីនៅណោះលោកគ្រូអើយ។

ក៖ ឆ្ងាយ......?

ខ៖ អើឆ្ងាយណាស់......!

ក៖ ខ្ញុំអត់ស្គាល់ដែរ?

ខ៖ ចាំឆ្ងាយ......!

ក៖ ចុះមីងគិតថាអើមីងមានចេះភាសាអីក្រៅពីភាសាខ្មែរអត់មីង?

ខ៖ អត់ទេលោកគ្រូអត់ចេះទេពីព្រោះយើងអត់មានម៉ែមានឪផ្គត់ផ្គង់ហាសលោកគ្រូ។

ក៖ ចឹងកាលជំនាន់មីងកើតមកក្មេងៗក៏គេអត់អោយរៀនបារាំង រឺក៏រៀនថៃវៀតណាមដែរ?

ខ៖ រៀនណាទេលោកគ្រូអើយរត់ប្រព្រឹត្តចាប់ព្រភីងជំនាន់ខ្ញុំលោកគ្រូអើ ខ្ញុំនៅឬស្សីកែវខ្ញុំទៅរៀននៅវត្តថ្មីហាសលោកគ្រូ។

ក៖ បាទមីង......!

ខ៖ ចាំ!ហើយកាលជំនាន់ណុងគេថាចាប់ក្មេងៗចាប់ក្មេងចាប់មែនតើលោកគ្រូ ដេញពួកខ្ញុំដើរទាំង ហ្នុងៗហ្នឹងលោកគ្រូ។

ក៖ បាទ......!

ខ៖ នៅតែវាដេញចាប់ទៀតហាស។

ក៖ បាទមីង......!

ខ៖
ដល់ពេលហើយម្ដាយខ្ញុំថាចេះកូនឯងឈប់រៀនទៅដល់ពេលឈប់រៀនទៅគាត់យកខ្ញុំទៅ ហ្នឹងទៅផ្ញើរនៅម្ដាយធំនៅឧត្ដុងកំពង់ហ្លួងហាសលោកគ្រូ។

ក៖ បាទមីងបាទៗស្គាល់។

ខ៖ ទៅក៏ទៅរៀនជាមួយលោក។

ក៖ អូ៎.......!

ខ៖ ចឹងវាអត់បានចេះហាសលោកគ្រូអើយចេះដែរប៉ុន្តែចេះតិចៗហាស។

ក៖ តិចៗហោសមីង......?

ខ៖ ចាំ!ទៅអាពតក៏អត់បានរៀន។

ក៖ អូ៎!បាទមីង......!

ខ៖ ចេញពីអាពតមកបានបងអោយរៀនបានតិចតួចហ្នឹងហាស។

ក៖
អូ៎បាទមីង!ចុះមីងគិតថាមីងធ្លាប់ធ្វើការងារអីគេខ្លះនៅក្នុងជីវិតរបស់មីងតាំងពីក្មេងរហូតម កដល់ ពេលនេះហាស?

ខ៖ អត់ទេ.......!

ក៖ ប៉ុន្តែមីងគិតថាមីងធ្លាប់ធ្វើស្រែរឺមួយក៏ធ្លាប់ធ្វើអីៗទេ?

ខ៖ អត់ទេ.......!

ក៖ អត់ដែរធ្វើទេណេះមីង?

ខ៖ ចាំ!ចង់និយាយអើចេញនៅជំនាន់អាពតចឹងគេធ្វើស្រែគេវែកដីហាសលោកគ្រូ។

ក៖ បាទមីង.......!

ខ៖ ខ្ញុំអត់ទេគេអោយឡើងភ្នំកាត់កន្ត្រាំងខែត។

ក៖ អូ៎.......!

ខ៖ សែងអាចម៍គោតាមផ្ទះហាសលោកគ្រូហាស។

ក៖ បាទមីងបាទ.......!

ខ៖ ចាំ!វាគ្រាន់ធូរប៉ុណ្ណឹងដែរ។

ក៖ ចុះ.......?

ខ៖
អើដល់ពេលនៅជំនាន់នេះអើជំនាន់ខ្ញុំគេធ្វើស្រែគ្រប់គ្នាបងខ្ញុំថាទៅរៀនទៅទុកអោយអញ់ធ្វើម្នាក់ឯង។

ក៖ ចឹងមីងអត់ដែរធ្វើស្រែទេ?

ខ៖ អត់ទេ........!

ក៖ អូ៎!បាទមីងចុះមីង?

ខ៖ ដល់ពេលដែរគេចែកដីហ្នឹងអើប្តីខ្ញុំធ្វើទៅ។

ក៖ អូ៎មីង.......?

ខ៖ ចឹងមួយឆាកជីវិតខ្ញុំអត់។

ក៖ អត់ដែរធ្វើការងារអីផ្សេងទេ?

ខ៖ អត់លំបាកទេទើបលំបាកឥឡូវហ្នឹងលោកគ្រូ។

ក៖ មី.......!

ខ៖ ចឹងគ្រូចឹងហាស។

ក៖ អ៊ំបាទមីង!ចុះមីងគិតថាមីងធ្លាប់ចិញ្ចឹមសត្វអីទេធ្លាប់ចិញ្ចឹមមាន់ ទា ជ្រូក គោ ក្របីអីទេ?

ខ៖ អត់ផងគោ ក្របី ចិញ្ចឹមតែមាន់លោកគ្រូ មាន់ជ្រូក។

ក៖ ប៉ុន្តែមីងចិញ្ចឹមជាលក្ខណៈធំមែន?

ខ៖ អត់ទេចិញ្ចឹមតូចតាចទ្រុងនៅក្រោយផ្ទះនេះលោកគ្រូ។

ក៖ អ៊ំបាទមីង.......!

ខ៖ ចិញ្ចឹមចឹងទៅដល់ពេលខ្ញុំយ៉ាប់ពេកខ្ញុំអោយកូនខ្ញុំលក់ទៅ។

ក៖ អ៊ំបាទចុះមីងគិតថាជីវិតរបស់មីងមានការផ្លាស់ប្តូរអីគេមីង
តាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖ អើនិយាយមិនផ្លាស់ប្តូរម៉េចលោកគ្រូ។

ក៖ មានការផ្លាស់ប្តូរអីគេខ្លះទៅមីង?

ខ៖ ផ្លាស់ប្តូរដូចជានៅក្មេងវាសុខវាស្រួលដោយសារជួបប៉ាហើយម៉ែវាស្រួលហាស។

ក៖ បាទមីង.......!

ខ៖ ទៅជំនាន់ផ្សេងៗទៀតគេពិបាកខ្ញុំស្រណុក។

ក៖ អ៊ំចឹងហោសមីង?

ខ៖ វាអត់សូវលំបាកទេចាំ ដល់ពេលជំនាន់ឥឡូវពិបាកតែចង់និយាយថាអត់ពិបាកកាយ
ពិបាកតែចិត្តហាសលោកគ្រូ។

ក៖ អ៊ំបាទមីងបាទ?

ខ៖ ចាំ.......!

ក៖ ចុះមីងគិតថាអើមីងចូលចិត្តពិសារម្ហូបអីគេដែរមីង?

ខ៖ ចាំ!ខ្ញុំហោស?

ក៖ បាទ........!

ខ៖ ខ្ញុំចូលចិត្តហូបតែស៊ុប។

ក៖ ហូបស៊ុបណោះមីងណោះ?

ខ៖ ចា៎......!

ក៖ ស៊ុបអីគេមីង?

ខ៖ ចា៎!ស៊ុបអីក៏ដោយអោយតែកូនធ្វើអោយខ្ញុំហូបបានទាំងអស់រីមួយទិញគេក៏បាន។

ក៖ អ៎ូ!បាទសំខាន់មីងចូលចិត្តហូបស៊ុប?

ខ៖ ចា៎!ប៉ុន្តែហូបអត់បានច្រើនទេតិចៗចោលហើយ។

ក៖ អ៎ូបាទ........!

ខ៖ កុំថាខ្ញុំមាឌធំចឹងហូបច្រើនហាសអត់ទេ។

ក៖ ចុះមីងគិតថាអើដូចជាតាំងពីក្មេងមីងចូលចិត្តលេងល្បែងប្រជាប្រិយ៍អីគេខ្លះមីង ដូចជាចោលឈូង ទាញព្រាត លាក់កន្សែងអីចឹងហាស?

ខ៖ អើលោកគ្រូកាលហ្នឹងខ្ញុំនៅតូចហោសមិនទៅលេងអីទេគ្រាន់តែឈរមើលគេហ្នឹង។

ក៖ អ៎ូចឹង......!

ខ៖ ហើយម្តាយខ្ញុំគាត់ឃាត់ឃាំងណាស់អត់អោយដើរទេ។

ក៖ ចឹងមីងអត់ដែរលេងទេចឹង?

ខ៖ ដូចថាគេមកលេងនិយាយរួមទៅថាផ្ទះខ្ញុំវាធំហាសលោកគ្រូ

ក៖ បាទមីង......!

ខ៖ អត់ដាំអីទេមុខផ្ទះ។

ក៖ បាទ......!

ខ៖ ទុកអោយអ្នកដទៃមកលេងផ្ទះខ្ញុំ។

កៈ អូចឹងណោះមីងណោះ?

ខៈ ចាំ......!

កៈ ប៉ុន្តែយើងអត់លេងទេយើងគ្រាន់តែឈរមើលគេលេង?

ខៈ លេងៗហ្នឹងគេហ្នឹងឯង។

កៈ អូលេង......!

ខៈ ចាំ!តែបើអោយទៅលេងផ្ទះគេម៉ែអត់អោយទៅទេ។

កៈ អូ!ប៉ុន្តែភាគច្រើនយើងចូលចិត្តលេងអីគេជាមួយពួកគាត់?

ខៈ លេងចូលឆ្នាំចឹងលេងរាំវង់រាំអីចឹងហាសលោកគ្រូ។

កៈ អូ......!

ខៈ ចាំ.......!

កៈ ចឹងមីងចូលចិត្តរាំ?

ខៈ អើ......!

កៈ ប៉ុន្តែមីងចូលចិត្ត......?

ខៈ ខេមរ៉ាដេញមាន់កូន។

កៈ មីងចេះច្រៀងអត់មីង?

ខៈ ខ្ញុំអត់ចេះទេលោកគ្រូ។

កៈ អត់ចេះច្រៀងទេណោះមីង?

ខៈ ចាំ......!

កៈ តែមីងចូលចិត្តស្តាប់បទចំរៀងអត់មីង?

ខៈ ចូលចិត្តហាសលោកគ្រូ។

កៈ ប៉ុន្តែលក្ខណៈបែបបទជាសម័យ រឺបទបុរាណដែរមីង?

ខ៖ អត់ទេបទបុរាណបទសម័យអត់ទេ។

ក៖ ប៉ុន្តែមីងមានជាមានចងចំណាងជើងបទចំរៀងដែរមីងគិតថាចាំមួយបទអីទេដែរមីងចូលចិត្តស្ដាប់ហាស?

ខ៖ បទអីក៏ចូលចិត្តស្ដាប់លោកគ្រូ។

ក៖ ឥលូវ.......?

ខ៖ តែបើបទឥឡូវចូលចិត្តតែមាសសុខសោភាច្រៀង។

ក៖ មាសសុខសោភាហោសមីង?

ខ៖ ចាំ......!

ក៖ ឥឡូវមីង.......?

ខ៖ ចាំ!ហើយហ្នឹងហឹមស៊ីវ៉ន។

ក៖ ឥឡូវមីងដាក់មួយឃ្លាទៅមីង?

ខ៖ អើអត់ចេះទេលោកគ្រូអើយ។

ក៖ អូ!និយាយលេងទេមីង?

ខ៖ ចាំ......!

ក៖ ចឹងមីងគិតថាមាននរណាគេមួយនៅក្នុងក្រុមគ្រួសាររបស់មីងចេះលេងឧបករណ៍ភ្លេងទេមីង?

ខ៖ អត់ទេលោកគ្រូមានតែកូនចេះធ្វើដែកចឹងហាស។

ក៖ អូ.......!

ខ៖ ចាំ......!

ក៖ ចឹងបងប្អូនកូនក្មួយអីក៏អត់ចេះដែរណោះមីងណោះ?

ខ៖ ចាំ!អត់ចេះទេលោកគ្រូ។

កៈ
ចុះមីងគិតថាផ្ទះរបស់មីងមានលក្ខណៈបែបណាតាំងពីក្មេងរហូតមកដល់ពេលនេះហាស ពីមុនផ្ទះម៉េចហើយឥឡូវផ្ទះម៉េចចឹងហាសមីង?

ខៈ ពីសង្គមខ្ញុំពីក្មេងហាសលោកគ្រូខ្ញុំផ្ទះខ្ញុំមួយចឹងផ្ទះគេមួយនៅជិតលក់ចឹងផ្ទះពីរ។

កៈ ប៉ុន្តែកាលណុងមីងនៅជាមួយឪពុកម្តាយមីង?

ខៈ ចាំ.......!

កៈ អូ៎........!

ខៈ ដល់ជំនាន់ឥឡូវនេះផ្ទះខ្លួនឯង។

កៈ អូ៎!ប៉ុន្តែផ្ទះរបស់មីងសព្វថ្ងៃហ្នឹងនរណាគេជាអ្នកសាងសងវាដែរមីង?

ខៈ ប្តីខ្ញុំ.......!

កៈ ប្តីមីងចេះធ្វើផ្ទះទេ?

ខៈ ចេះ......!

កៈ អូ៎!គាត់ចេះមកពីនរណាគេដែរមីង?

ខៈ ចេះពីឪពុកគាត់។

កៈ អូ៎!ចឹងមានន័យថាគ្រួសាររបស់គាត់ចេះតៗគ្នាហាសណេះមីង?

ខៈ ចាំ!អើឪពុកគាត់ចេះធ្វើផ្ទះ ចេះធ្វើធ្វើថៅកែស៊ីខ្លួថៅកែអីហាសលោកគ្រូ។

កៈ អូ៎!ឡូយហាសណេះមីងណេះ?

ខៈ ឡូយតើនៅពេទ្យលោកសង្ឃហាសលោកគ្រូ។

កៈ ឥឡូវហ្នឹងហោសមីង?

ខៈ ចាំអត់ទេ.......!

កៈ ពីមុន.......?

ខ៖ គាត់បើកចាំចង់និយាយថាអើឥឡូវណាលោកគ្រូដល់មកពីអាពតមកអត់ទាន់ទេ
គេមកនៅផ្ទះ។

ក៖ អូ៎បាទ.......!

ខ៖ ចុះមីងគិតថាផ្ទះរបស់មីងធ្វើហ្នឹងគេប្រើឧបករណ៍អីសំរាប់សាងសងផ្ទះមួយហ្នឹងមីង
មានឧបករណ៍អីគេខ្លះទៅ?

ខ៖ ដឹងអីលោកគ្រូមានដូចជាមានឧបករណ៍។

ក៖ ដែកគោល ឈើ.....?

ខ៖ ចាំ!មានដែកគោល......។

ក៖ ឬស្សី.......?

ខ៖ ឈើ រណា ពូថៅអីចឹងហាសលោកគ្រូ។

ក៖ ពន្លាក់អីចឹងណេះមីង?

ខ៖ ចាំ........!

ក៖ អូ៎!បាទមីងចុះមីងគិតថាជំនាញអីដែរមីងចេះស្ទាត់ជំនាញម៉ងហាស
ដែរមីងអាចធ្វើបានហាសមីង?

ខ៖ ដែរអាចធ្វើបានគ្រូហោសរាល់ថ្ងៃជំនាញជាងគេលក់ត្រី។

ក៖ លក់ត្រីហោសមីង?

ខ៖ ចាំ!លក់ត្រីប្ដីរកមកខ្ញុំអ្នកលក់។

ក៖ មីងទៅលក់នៅណាមីង?

ខ៖ លក់ភូមិលោកគ្រូលក់ត្រឹមសាម សែសិបម៉ឺនអីលក់តែមួយភ្លេតហ្នឹងហាស។

ក៖ អូ៎!ឡូយហាសណេះមីង?

ខ៖ អូ៎!ឡូយតើលោកគ្រូតែ.......។

ក៖ ប៉ុន្តែលក់នៅក្នុងភូមិហ្នឹងទេណោះមីង?

ខ៖ ចាំលោកគ្រូ.......!

ក៖ អូ!ចុះមីងគិតថាអើឪពុកម្ដាយរបស់មីងធ្លាប់បង្រៀនពីជំនាញអីទៅមីងទេ?

ខ៖ អត់ផងលោកគ្រូកាលណុលពួកខ្ញុំនៅតូចៗពេកហាស។

ក៖ បាទមីង.......!

ខ៖ មានតែទៅអោយទៅរៀន។

ក៖ ចុះលក្ខណៈដូចធ្វើកន្ទេលធ្វើល្អី ធ្វើវេញវល្លិ៍កូរស្ករអីមីងធ្លាប់ធ្វើពីមុនទេ?

ខ៖ អត់ធ្លាប់ធ្វើទេផ្ទះខ្ញុំហ្នឹងអើផ្ទះខ្ញុំនៅជាប់ជិតផ្សារដែរហ្នឹងលោកគ្រូ។

ក៖ អូ!បាទមីងបាទចុះមីងអាចប្រាប់ពីពេល.......?

ខ៖ អូនជូតច្រមុះអោយប្អូនចេញអូន។

ក៖ មីងអាចប្រាប់ពីពេលអើដំបូងដែរមីងលំបាកតាំងពីក្មេងរហូតដល់ពេលនេះបានទេមីង មីងធ្លាប់ជួបការលំបាកអីគេខ្លះនៅក្នុងជីវិតរបស់មីងចឹងហាស?

ខ៖ លោកគ្រូតាំងពីក្មេងមកឥឡូវខ្ញុំទើបតែលំបាកឥឡូវហ្នឹង។

ក៖ មីងលំបាកអីគេខ្លះឥឡូវហ្នឹង?

ខ៖ លំបាកមើលចៅ
លំបាកចិត្តកូនកូនអត់ធ្វើអីពិបាកចិត្តគ្រាន់តែថាវាជំពាក់គេចឹងលោកគ្រូអើយ។

ក៖ អូ!កូនមីងមានក្រុមគ្រួសារទាំងអស់គ្នាហើយចឹងមីង?

ខ៖ ទាំងអស់គ្នាទេតែជំពាក់ចឹងទៅខ្ញុំជាអ្នកចេញសងហ្នឹង។

ក៖ អើម៉េចចឹងមីង?

ខ៖ ចឹងបានន័យថាកូនជំពាក់ម៉ែសងគ្រាន់តែលំបាកតែប៉ុណ្ណឹងទេលោកគ្រូ។

ក៖ រួចពួកគាត់........?

ខ៖ តែពួកគាត់អត់រកសងខ្លួនឯងទេណោះមីង?

ខ៖ រកៗអត់ទាន់លោកគ្រូ អត់ទាន់ចឹងហាស។

ក៖ អុំ.......!

ខ៖ តែមើលថៅអីចឹងខ្ញុំមិនថ្មញទេប៉ុណ្ណឹងលោកគ្រូអើយ។

ក៖ ប៉ុន្តែនៅជំពាក់គេច្រើនមែនទេមីងចុះ.......?

ខ៖ ចឹងបានខ្ញុំដាក់ផ្លាក់លក់ដីហ្នឹងហាស។

ក៖ អុំ.........!

ខ៖ ចាំ.......!

ក៖ ចឹងចុះអើដូចជា.......?

ខ៖ មួយឆាកជីវិតខ្ញុំហ្នឹងទើបតែលំបាកឥឡូវហ្នឹង។

ក៖ បាទមីងបាទ.......!

ខ៖ ដូចខ្ញុំនិយាយប្រាប់លោកគ្រូចឹងនៅពីសង្គមខ្ញុំដឹងតែទៅរៀនម៉ង។

ក៖ បាទមីងបាទ........!

ខ៖ នៅជំនាន់អាពតទៅកាច់កន្ត្រាំងខែតដែរ។

ក៖ បាទ.......!

ខ៖ ហើយហ្នឹងលើកអាចម៍គោតាមផ្ទះបន្តិចបន្តួចចឹង។

ក៖ បាទមីង.......!

ខ៖ ប៉ុន្តែបើគេរែកដីហាសលោកគ្រូ។

ក៖
បាទ!ចុះមីងគិតថាអើសំរាប់ដូចជាអើមីងកូនរបស់មីងហ្នឹងគាត់នៅផ្ទះបែកពីមីងទាំងអស់គ្នាមែន?

ខ៖ ចាំបែក.......!

កៈ គាត់នៅជាមួយក្រុមគ្រួសារគាត់រៀងខ្លួនទាំងអស់គ្នាណោះមីងណោះ?

ខៈ ចាំ.......!

កៈ ប៉ុន្តែគាត់រកស៊ីធ្វើអីគេខ្លះទៅមីង?

ខៈ អើនេះអើផ្សារដែកប្រពន្ធធ្វើការងាររោងចក្រហាសលោកគ្រូ។

កៈ បាទមីង........!

ខៈ ហើយមួយទៀតអើកូនបង្កើតខ្ញុំប្រុសដែរតែផ្សារដែកចឹងដែរ
អើប្រពន្ធធ្វើការងាររោងចក្រតែគេនៅទួលពង្រ។

កៈ បាទ........!

ខៈ តែគេទិញផ្ទះល្វែងនៅហាសលោកគ្រូ។

កៈ បាទមីងបាទ.......!

ខៈ ចាំ!ហើយមួយទៀតដាំផ្កានៅនោះព្រៃកហូ។

កៈ កូនមីងប៉ុន្មាននាក់ទាំងអស់?

ខៈ ប្រាំមួយលោកគ្រូ។

កៈ ប្រាំមួយនាក់ហោស?

ខៈ ចាំ!រៀបចំបួនហើយ។

កៈ នៅពីរនាក់ទៀតហោស?

ខៈ នៅពីរនាក់ទៀត។

កៈ អូ៎!បាទមីង
ចុះមីងគិតថាកាលពីក្មេងមីងចឹងមីងកាលពីក្មេងអត់ធ្លាប់ជួបការលំបាកអីទេណោះមីង?

ខៈ អត់ទេលោកគ្រូដើមស្រូវខ្ញុំអត់ស្គាល់ផង។

កៈ អ៎ូ.......!

ខ៖ ខ្ញុំស្គាល់នៅអាពតទេ។

ក៖ បាទមីង!ចុះមីងគិតថាកាលជំនាន់ប៉ុលពតមីងមានការលំបាកអីគេខ្លះទៅមីង?

ខ៖ ខ្ញុំលំបាកអត់ហូបលោកគ្រូដូចវាថាការងារហាស
ដូចខ្ញុំនិយាយចឹងលោកគ្រូអាយុប៉ុនខ្ញុំគេអោយ រែកដីហាស។

ក៖ បាទមីងបាទ.......!

ខ៖ ចំណែកខ្ញុំគេអោយអើសែងអាចម៍តាមផ្ទះ ហ្នឹងឡើងភ្នំកាចកន្ទ្រាំងខែតយកមកធ្វើជី។

ក៖ ប៉ុន្តែកាលណុងគេអោយមីងទៅណាទៅ?

ខ៖ អើទៅបាត់ដំបងលោកគ្រូ។

ក៖ អូ៎!យើងលក្ខណៈយើងទៅជាគ្រួសាររឺមួយក៏យើងទៅម្នាក់ឯងទេមីង?

ខ៖ មិនមែនទេទៅទាំងគ្រួសារលោកគ្រូតែទៅដល់នោះ......។

ក៖ គេបំបែកគ្នា.......?

ខ៖ ចា៎!បំបែកដូចយើងទៅតាមដូចខ្ញុំកុមារទៅនៅកុមារ បងខ្ញុំនារីទៅខាងនារី។

ក៖ អូ៎បាទមីង.......!

ខ៖ គ្រាន់តែទៅដល់បុកភ្លូមគេយកបងខ្ញុំទៅរាប់ឆ្នាំម៉ងហាសលោកគ្រូ។

ក៖
បាទមីង!ចុះមីងគិតថារយះពេលប៉ុន្មានខែប៉ុន្មានឆ្នាំបានគេអោយយើងជួបក្រុមគ្រួសារយើងម្តងអីចឹង ហាសរឺមួយក៏មកលេងម៉ាក់ប៉ាម្តងអីចឹងហាសមីង?

ខ៖ មែនទេលោកគ្រូយើងចង់មកចឹងសុំគេមកគេអោយមកក៏មកទៅ
តែបើគេអត់មកទៅវិញគេហ្នឹង ដាក់ពិន័យយើងហាសលោកគ្រូ។

ក៖ បាទ.......!

ខ៖ ដូចជារែកដីរែកអីចឹងទៅណាស់។

ក៖ ប៉ុន្តែគេអោយមកមករយះពេលយូររឺមួយក៏រយះពេលខ្លី?

ខ៖ អត់យូរទេលោកគ្រូអើយមួយយប់អីហ្នឹងប្រឹងហើយ។

ក៖ អ៎ូ!ហ្នឹងគេអោយយើងគេងជាមួយឪពុកម្ដាយមួយយប់ទៅ។

ខ៖ ចាំ.......!

ក៖
អ៎ូ!ប៉ុន្តែចុះមីងគិតថារបបអាហារកាលមីងនៅកុមារហ្នឹងមីងគិតថាអាហារគ្រាប់គ្រាន់ទេមីង?

ខ៖ កាលខ្ញុំនៅពីសង្គមហ្នឹងហោសលោកគ្រូ?

ក៖ កាលនៅជំនាន់ប៉ុលពតហាសមីង?

ខ៖
អ៎ូ!នៅប៉ុលពតអត់បាយហូបទេលោកគ្រូចឹងម៉ាក់ហើយប៉ាខ្ញុំហ្នឹងអត់ស្លាប់ហ្នឹងមិនមែនគេវៃចោលទេ។

ក៖ ដោយសារអត់មាន.......?

ខ៖ គឺអត់បាយហូប។

ក៖ អត់ឃ្លានណោះមីង?

ខ៖ ចាំ!វាអត់អោយអំបិលហូបទេ ចង់និយាយថាយើងមានមាស
យើងមានខោអាវស្អាតៗយើងហាសលោកគ្រូប្ដូរបានហូបហាសហើយដល់ពេលអស់អាហ្នឹងទៅយើងហូបសាបវាមិនហើម។

ក៖ បាទមីង.......!

ខ៖ ហើមបណ្ដាលអោយយើងឈឺស្លាប់។

ក៖ អ៎ូ!ចឹងហោសមីងហោស?

ខ៖ ចាំ!អើខាងខ្ញុំគេអត់សូវវៃចោលទេច្រើនតែបង្អត់ចឹងម៉ង។

ក៖ បាទមីងបាទ.......!

ខ៖ ចឹងយើងអត់ចឹងយើងចេះតែអត់បោចនេះអីហូបបណ្ដាលអោយវាហើមចឹងហាស។

កៈ បាទមីងបាទ.......!

ខៈ ចាំ.......!

កៈ អូ!ចុះមីងគិតអើមីងឆ្លងកាត់ការឧបសគ្គទាំងអស់ហ្នឹងដោយរបៀបម៉េចដែរមីង?

ខៈ
អើនិយាយរួមទៅវេទនាណាស់លោកគ្រូអើយនៅជំនាន់ប៉ុលពតហ្នឹងវេទនាណាស់ដូចបង
ខ្ញុំហោសបើកមុខបបរមកដូចគេនិយាយអត់ខុសទេលោកគ្រូ
ដូចថាមួយខ្ទះហ្នឹងដាក់តែបីកំប៉ុងចឹងហាស។

កៈ បាទមីង.......!

ខៈ វាចែកមកឡើងរាវ ចែកមកចឹងពេលខ្ញុំយកស្លាបព្រាហូបចឹងខេមរ៉ា
ពេលខ្ញុំយកស្លាព្រាមកហូបចឹងកុំអាលហូបចាំបេះបន្លែថែមសិនលើកបបរហ្នឹងដាក់លើភ្លើង
ហាសលោកគ្រូ ហើយបេះផ្ទីបេះអីដូចជាស្លឹកវល្លិ៍ព្រៃអីអាចចឹងហាសណាស់។

កៈ ដាក់ឆៅម៉ង......?

ខៈ មិនមែនទេដាក់លើភ្លើងចឹងអោយវាស្លោកទៅ។

កៈ អូ........!

ខៈ បានបានហូប.......!

កៈ អូបាទមីង.......!

ខៈ ចាំ.......!

កៈ អូចុះ.......?

ខៈ វេទនាហាសលោកគ្រូអើយ។

កៈ មីងគិតថាពេលណាដែរសប្បាយជាងគេនៅក្នុងជីវិតរបស់មីងដែរ
ចាប់ពីពេលណាទៅមីង?

ខៈ ចាប់ពីពេលជួបប្តីខ្ញុំមកហ្នឹង។

កៈ អូ!ពេលហ្នឹងគាត់......?

ខៈ ខ្ញុំចាំខ្ញុំសប្បាយរហូតដល់ខ្ញុំមានកូនមានកូនទើបពិបាកចិត្តនៅពេលមានកូនហ្នឹង

កៈ អូបាទ......!

ខៈ ចាំ......!

កៈ ចុះមីងគិតថាកាលពីក្មេងមីងធ្លាប់មានក្តីស្រម៉ៃថាពេលធំឡើង មីងចង់ធ្វើអីទេ?

ខៈ
អត់ចង់សម័យធ្វើអីទេព្រោះអីគ្រាន់តែសម័យថាចង់អើសម័យអោយមានទៅជាការស្រេច ហើយមានផ្ទះថ្ម ផ្ទះអីនៅចឹងហាស។

កៈ បាទមីងបាទ.......!

ខៈ អត់ចង់បានអីធំដុំទេណាស់លោកគ្រូ។

កៈ
បាទមីងបាទ!ចុះបើសិនជាចង់អោយមីងផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗមីងចង់ផ្ដែផ្ដាំអីទៅគាត់ដែរមីង?

ខៈ ចង់ផ្ដែផ្ដាំថាមិនដឹងថាម៉េចទេលោកគ្រូនេះ។

កៈ ចង់អោយគាត់ខំប្រឹងរៀន?

ខៈ ចាំ.......!

កៈ ដើម្បីអោយគាត់.......?

ខៈ ចាំ.......!

កៈ មានអនាគត់ល្អអីចឹងហាស?

ខៈ
ចាំ!ចង់ផ្ដាំទៅផ្ដាំទៅកូនចៅជំនាន់ក្រោយអោយខំរៀនកុំអោយដូចមីងមីងអត់សូវចេះប៉ុន្មានទេ។

កៈ បាទមីងបាទ.......!

ខៈ
ចេះអាចមើលរួចចឹងកូនចៅខំរៀនទៅហ្នឹងអាចបានធ្វើការធំដុំហ្នឹងអើរកទទួលទានមានបាន ហើយហ្នឹងដូចថាមានលុយទិញឡានទិញវីឡាអីនៅចឹងហាស។

កៈ ចុះបើសិនជាមីងចង់អោយពួកគាត់ជៀសវៀងវិញពីអំពើមួយដែរអត់ល្អចឹងហាស?

ខៈ អើ......!

កៈ ភាគច្រើនអោយគាត់ជៀសវៀងអីគេមីង?

ខៈ អើជៀសវៀងអើថ្នាំញៀនហើយហ្នឹងហូបស្រានៅពេលបើកបរហាសលោកគ្រូ។

កៈ បាទមីងបាទ........!

ខៈ ចាំ.......!

កៈ មានអីផ្សេងទៀតដែរមីងចង់ផ្តែផ្តាំផ្សេងទៀតទេ?

ខៈ អត់ទេលោកគ្រូ។

កៈ
បាទ!ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនមីងដែរបានអោយខ្ញុំពិភាក្សាជាមួយមីងទាក់ទងពីប្រវត្តិរបស់មីង។

ខៈ ចាំ.......!

កៈ
ហើយខ្ញុំហ្នឹងដាក់ការសម្ភាសទាំងអស់នេះទៅក្នុងវេបសាយសាលាដើម្បីតំកល់ទុកអោយមីង?

ខៈ ចាំ.........!

កៈ
ចឹងជាចុងក្រោយខ្ញុំជូនពរមីងដើម្បីអោយមានសុខភាពល្អហើយមីងអាចសំរេចនូវគោលបំណង ដែរមីងអាចជួយកូនរបស់មីងអីចឹងហាសមីង?

ខ៖ ចាំ.......!

ក៖ បាទ!ចឹងអរគុណច្រើនមីង។

ខ៖ ចាំ......។